# សុន្ទរកថា ឯ.ឧ. អៀង មូលី
# ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
# ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

(ក្នុងឱកាសចូលកាន់តំណែង នៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣)

- សូមគោរព ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ។
- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដៃគូអភិវឌ្ឍន៍
- ភ្ញៀវកិត្តិយសទាំងអស់ជាទីគោរពរាប់អាន ។

ថ្ងៃនេះចាត់ទុកជាមហាកិត្តិយស ចំពោះអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលបានរៀបចំពិធីផ្ទេរតំណែងនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃរាជរដ្ឋាភិបាលកម្ពុជា ។

វត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ នាឱកាសនេះ បានបញ្ជាក់ឲ្យឃើញនូវការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ដែលជាគ្រោះភ័យមួយបង្កើតឡើងដោយមនុស្ស និង ដែលបង្កផលវិបាកច្រើនជំពូក និង យ៉ាងធំធេងដល់សង្គមមនុស្សទៀតផង ។

- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរព

ខ្ញុំសូមឆ្លៀតឱកាសដ៏កម្រនេះ ដើម្បីសម្តែងជូននូវការគោរព និង កោតសរសើរ ដ៏ស្មោះរបស់ខ្ញុំ ចំពោះបទពិសោធន៍ដ៏ថ្លៃថ្លារបស់ឯកឧត្តម ក្នុងការបម្រើជាតិមាតុភូមិកម្ពុជា នៅគ្រប់កាលៈទេសៈអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។ ខ្ញុំសូមសំដែងការកោតសរសើរជាពិសេស ចំពោះតួនាទីដ៏សំខាន់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលឋិតនៅក្រោមបញ្ជាដ៏ឈ្លាសវៃរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីដឹកនាំសេដ្ឋកិច្ចជាតិ ឲ្យមានការរីកចំរើនឥតឈប់ឈរ ពីមួយឆ្នាំ ទៅមួយឆ្នាំ ធ្វើឲ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់បាននូវអតិផរណាគួរជាទីពេញចិត្តគឺ ក្នុងរង្វង់ ៤,២% ក្នុង ១ ឆ្នាំ និង កាត់បន្ថយភាពក្រីក្រឲ្យចុះថយ ១%ក្នុង ១ ឆ្នាំ យ៉ាងទៀងទាត់ និងគួរជាទីមោទនៈ ។ អ្វីដែលខ្ញុំត្រូវរៀនសូត្រពីឯកឧត្តមឧបនាយករដ្ឋមន្ត្រីនោះគឺ ភាពជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាព តាមរបៀបដែលខ្ញុំវាយតម្លៃថា "ទន់ភ្លន់ តែម៉ឺងម៉ាត់" ។

ជាមួយគ្នានេះដែរ ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងការកោតសរសើរ ចំពោះថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ក្រោមការដឹកនាំប្រកប ដោយសមត្ថភាពខ្ពស់នៃឯកឧត្តម ទេសរដ្ឋមន្ត្រី **នុត សុខុម** នៅក្នុងអាណត្តិកន្លងទៅ ដែលបានបំពេញភារកិច្ចសម្រេចបានសមិទ្ធផលជាច្រើន ដែលលេចចេញលទ្ធផលជាផ្លែផ្កា គួរជាទីពេញចិត្ត ធ្វើឲ្យប្រទេសយើងស្ថិតនៅក្នុងចំណោមប្រទេសតិចតួចក្នុងសកលលោក ដែលបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស ។ អ្វីដែលយើងត្រូវគូសបញ្ជាក់នូវសមិទ្ធផលគួរកត់សំគាល់នោះគឺ កម្ពុជាយើងទទួលបានពានរង្វាន់អង្គការសហប្រជាជាតិ ដែលមានឈ្មោះថា**ពានរង្វាន់របស់អង្គការសហប្រជាជាតិជូនប្រទេសកម្ពុជា** ដែលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ឲ្យបាន ៥០ %មុនឆ្នាំ ២០១៥ (UN Award for Achieving Millenium Development Targets on AIDs) ។

ជាមួយនឹងការកោតសរសើរនេះ ខ្ញុំក៏សូមជូនពរឯកឧត្តម ទេសរដ្ឋមន្ត្រី **នុត សុខុម** និង ក្រុមគ្រួសារ សូមឲ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ សិរីសួស្តី និង ជ័យជំនះធំៗក្នុងភារកិច្ចថ្មីទៀតរបស់ឯកឧត្តម នាពេលខាងមុខ ។

- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរពរាប់អាន

ការងារប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ ជាការងារពហុវិស័យ ដែលតម្រូវឲ្យមានការចូលរួមសហការយ៉ាងទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន ទាំងពីផ្នែករដ្ឋគ្រប់ជាន់ថ្នាក់ ពីផ្នែកឯកជន ពីដៃគូអភិវឌ្ឍន៍ ពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ពីសង្គមស៊ីវិល និង ពីប្រជាពលរដ្ឋទាំងមូលផង ទើបអាចសម្រេចជោគជ័យបាន ។ ដូច្នេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ត្រូវខឹតខំបំពេញភារកិច្ចជាអ្នកនាំមុខ ចាត់វិធានការផង និង ជាអ្នកសម្របសម្រួលផង នាំឲ្យមានកិច្ចសហការគ្នាល្អ និង សុខដុមនីយកម្ម រវាងប្រតិបត្តិករទាំងអស់ ដើម្បីអប់រំ ផ្សព្វផ្សាយឲ្យបានទូលំទូលាយជាទីបំផុត ឲ្យមានការយល់ដឹងជាសាធារណៈ អំពីមហន្តរាយនៃជម្ងឺអេដស៍ កុំឲ្យមានការរើសអើងចំពោះអ្នកកើតជម្ងឺអេដស៍ ឲ្យមានការចេះដឹងក្នុងការទប់ស្កាត់ និង បង្ការកុំឲ្យមានការរីកដាលនៃមេរោគអេដស៍ និង ជួយថែទាំព្យាបាល និង ផ្តល់សេវាសុខាភិបាលជូនដល់អ្នកផ្ទុកមេរោគអេដស៍ឲ្យបាន ១០០ % ។ អត្រាសេសសល់នៃអ្នកផ្ទុកមេរោគអេដស៍ ដែលមិនទាន់បានទទួលសេវាសុខាភិបាលក្នុងការថែទាំ ឬ ព្យាបាល ទោះជាអត្រានោះនៅសល់តិចតួចក៏ដោយ ក៏នៅតែជាហានិភ័យខ្ពស់សម្រាប់ប្រជាពលរដ្ឋខ្មែរយើង ព្រោះថាការចម្លងមេរោគអេដស៍អាចកើតមានគ្រប់ពេលវេលា ប្រសិនបើយើងមានការធ្វេសប្រហែស ឬ មិនបានយកចិត្តទុកដាក់ចាត់វិធានការឲ្យបានសមស្រប ។

ដើម្បីកំណត់ឲ្យកាន់តែជាក់លាក់ ឲ្យកាន់តែច្បាស់លាស់ នូវចំនួនអ្នកផ្ទុកមេរោគអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ត្រូវតែបន្តបំផុសចលនាមហាជន ឲ្យស្ម័គ្រចិត្តមកធ្វើតេស្តមេរោគអេដស៍ឲ្យបានជាប្រចាំ និង ផុសផុលឡើងថែមទៀត ។ យើងត្រូវបន្តអនុវត្តឲ្យបានជោគជ័យ នូវគំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និង ជម្ងឺអេដស៍លើកទី ៣ (២០១១--២០១៥) ។ ជាមួយនេះ អាជ្ញាធរជាតិប្រឆាំងនឹងជម្ងឺអេដស៍ នឹងធ្វើការវាយតម្លៃលើវឌ្ឍនភាព នៃការអនុវត្តយុទ្ធសាស្ត្រទាំង ៧ នៃគំរោងផែនការយុទ្ធសាស្ត្រខាងលើ ។ បន្ទាប់មក យើងនឹងធ្វើការរួមគ្នាជាមួយអ្នកជំនាញការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើបញ្ជីសារពើភណ្ឌអំពីបញ្ហាប្រឈម អំពីដំណោះស្រាយ អំពីតម្រូវការ និង ប្រភពធនធាន ដែលជាជំនួយក្នុងការរៀបចំគំរោងផែនការយុទ្ធសាស្ត្រលើកទី ៤ (២០១៦-២០២០) តទៅមុខទៀត ។

- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព រាប់អាន

ខ្ញុំសូមសារភាពថា ខ្ញុំមិនមែនជាអ្នកជំនាញវេជ្ជសាស្ត្រ ឬ ជាអ្នកជំនាញប្រយុទ្ធនឹងជម្ងឺអេដស៍ ឬ ជាអ្នកជំនាញខាងសេវាសង្គមនោះទេ ខ្ញុំប្រាកដជាត្រូវការការចូលរួមយ៉ាងពេញទំហឹង និង យ៉ាងសកម្មពីអ្នកជំនាញទាំងនោះ ។ ខ្ញុំសង្ឃឹមថាសហាសេវិកនៅក្នុងអាជ្ញាធរជាតិនេះ ដែលមួយចំនួន ជាអ្នកជំនាញពិតប្រាកដនឹងផ្តល់នូវកិច្ចសហការដ៏មានតម្លៃ ដើម្បីចូលរួមចំណែក ធ្វើឲ្យបេសកកម្មរបស់យើងក្នុងការប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ សម្រេចបានជោគជ័យសមតាមក្តីប្រាថ្នារបស់យើងទាំងអស់គ្នា និង ទៅតាមគោលដៅក្នុងតួនាទីដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ឲ្យនោះ ។ ចំពោះរូបខ្ញុំ ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ខ្ញុំនឹងខឹតខំបំពេញភារកិច្ចដឹកនាំស្ថាប័នជាតិមួយនេះ ដោយយកចិត្តទុកដាក់ជាទីបំផុត ធ្វើឲ្យមានការរីកចំរើន ជានិច្ចនិរន្ត៍ ពង្រឹងសាមគ្គីភាពផ្ទៃក្នុង ធ្វើឲ្យមានភាពសុខដុមរមនាក្នុងការងារពង្រីកទំនាក់ទំនងខាងក្រៅ ខឹតខំគៀងគរស្វែងរកជំនួយពីគ្រប់ដៃគូអភិវឌ្ឍន៍ និង ប្រទេសជាមិត្តទាំងឡាយ ដើម្បីឲ្យសកម្មភាពប្រយុទ្ធប្រឆាំងជម្ងឺអេដស៍រឹតតែមានប្រសិទ្ធភាពខ្ពស់ ។ ខ្ញុំសូមប្តេជ្ញាថា នឹងនាំមកជាមួយនូវសុឆន្ទៈដ៏បរិសុទ្ធ និង ការតាំងចិត្តដ៏មុតមាំ ក្នុងការបម្រើស្ថាប័នជាតិមនុស្សធម៌នេះស្របតាមអនុសាសន៍ ក៏ដូចជាការចង្អុលបង្ហាញពីរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងនូវកត្តញ្ញុតាធម៌ដ៏ជ្រាលជ្រៅជូន សម្តេចតេជោ ដែលបានផ្តល់សេចក្តីទុកចិត្ត ចាត់ខ្ញុំឲ្យមកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍នៅក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាលនេះ ។

មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ និង ប្រទេសជាមិត្តទាំងអស់សូមមេត្តាផ្តល់ និង បន្តផ្តល់ជំនួយដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលជាជំនួយមនុស្សធម៌សុទ្ធសាធ ដើម្បីឲ្យយើងខ្ញុំមានលទ្ធភាព ធ្វើការទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍ និង ផ្តល់សេវាថែទាំ និង ព្យាបាលអ្នកមានជម្ងឺអេដស៍ ដែលកំពុងត្រូវការ ឲ្យទាន់ពេលវេលា និង ឲ្យបានទូលំទូលាយតទៅ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ដែលបានផ្តល់កិត្តិយសអញ្ជើញជាអធិបតីនៃពិធីផ្ទេរ

តំណែងនាថ្ងៃនេះ និង សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយសទាំងអស់ ដែលបានចូលរួមក្នុងពិធីនេះ ញ៉ាំងឲ្យពិធីនេះរឹងរឹតតែមានភាពអធិកអធមជាអតិបរិមា ។ ខ្ញុំសូមជូនពរឯកឧត្តម គណៈអធិបតី អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ សូមឲ្យបានជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ